ទីក្រុងហាណូយ ថ្ងៃទី ៣១ មករា ១៩៣៩

**{Jules Brévié}**

**អគ្គទេសាភិបាលឥណ្ឌូចិន**

លិខិតលេខ 367-API Grand Officier de la Legion d'Honneur

**ផ្ញើជូន លោកអភិបាល កូសាំងស៊ីន នៅទីក្រុងសាយហ្គន**

**កម្មវត្ថុ៖** ចង្កោមកោះ នៅឈូងសមុទ្រសៀម

ខ្ញុំសូមជម្រាបលោក {អភិបាលកូសាំងស៊ីន} ថា ខ្ញុំទើបនឹងបានពិនិត្យមើលសារជាថ្មី ម្តងទៀត នៅលើចំណោមរឿង ចង្កោមកោះ ដែលនៅក្នុងឈូងសមុទ្រ សៀម ដែលមានការទាស់ទែងគ្នា រវាងប្រទេសកម្ពុជា និងកូសាំងស៊ីន។

ស្ថានភាពនៃចង្កោមកោះនេះ ដែលមានរាយ នៅតាមបណ្តោយ ឆ្នេរសមុទ្រខ្មែរ ហើយដែលមានខ្លះ ស្ថិតនៅសែនជិតឆ្នេរសមុទ្រ របស់ខ្មែរ ដែលដី(ល្បាប់) ដែលកំពុងដុះ និងចេះតែបន្តដុះនេះ នឹងភ្ជាប់កោះទាំងនេះ ទៅនឹងឆ្នេរសមុទ្រ របស់ប្រទេសកម្ពុជា ក្នុងរយៈពេលដ៏ខ្លីខាងមុខនេះ។ តាមការសមហេតុសមផល និង តាមរបៀបភោគម្តសាស្ត្រ ជាការចាំបាច់ ត្រូវតែដាក់កោះទាំងនេះ ឲ្យនៅក្រោមការត្រួតត្រា នៃរាជការប្រទេសកម្ពុជា។ ខ្ញុំមិនអាចនឹងទុកស្ថានភាព ដែលមានសព្វថ្ងៃនេះ បង្ខំឲ្យ ប្រជាពលរដ្ឋ ដែលរស់នៅលើកោះទាំងនេះ បង្ខំចិត្ត ឬមួយ ឆ្លង កាត់សមុទ្រយ៉ាងឆ្ងាយ ឬមួយត្រូវវាងកាត់តាមទឹកដីប្រទេសកម្ពុជា ដើម្បីទៅទាក់ទងនឹងរដ្ឋការកូសាំងស៊ីន បន្តទៅមុខទៀតបាន នោះទេ។

ហេតុនេះ ខ្ញុំសម្រេចថា កោះទាំងឡាយណា ដែលនៅខាងជើងខ្សែ បន្ទាត់មួយ ដែលកាត់កែង នឹងឆ្នេរសមុទ្រ គិតពីចំណុចព្រំប្រទល់ រវាងប្រទេសកម្ពុជា និង កូសាំងស៊ីន ហើយដែលមានមុំ ១៤០ អង្សារ ជាមួយនឹងភាគខាងជើងនៃខ្សែវណ្ណ ដូចមានក្នុងផែនទី ដែល មានភ្ជាប់មកជាមួយនេះ ចាប់ពីថ្ងៃនេះតទៅ នឹងត្រូវគ្រប់គ្រង ដោយប្រទេសកម្ពុជា។

រដ្ឋការអាណាព្យាបាល មានភារកិច្ចជាពិសេស នៅក្នុងផ្នែកប៉ូលីស នៅលើកោះទាំងនេះ។ កោះទាំងឡាយ ដែលស្ថិតនៅខាងត្បូង ខ្សែបន្ទាត់នេះ សរុបទាំង កោះហ្វូកុក ទាំងមូល ត្រូវនៅក្រោមការគ្រប់គ្រងរបស់ កូសាំងស៊ីន តទៅទៀត។ ត្រូវដឹងថា ខ្សែបន្ទាត់ខណ្ឌសីមា ដែលបានកំណត់នេះ ព័ទ្ធកោះហ្វូកុក តាមភាគខាងជើង ដោយនៅចម្ងាយ ៣ គីឡូម៉ែត្រ ពីចំណុចនានា ដែលនៅខាងជើងបំផុត នៃកោះនេះ។ ការធ្វើរបៀបនេះ អំណាចរដ្ឋបាល និងអំណាចប៉ូលីស នៅលើកោះទាំងអស់នេះ នឹងត្រូវចែកយ៉ាងដាច់ពីគ្នា រវាងកូសាំងស៊ីន និង ប្រទេសកម្ពុជា ដើម្បីចៀសវាងការទាស់ទែងគ្នា ទៅអនាគត។ ក៏ប៉ុន្តែ នេះគ្រាន់តែជា «ការគ្រប់គ្រងផ្នែករដ្ឋបាល និងប៉ូលីសប៉ុណ្ណោះ» ចំណែកបញ្ហាអនិស្សរភាព (ក្រោមចំណុះ) (De pendanco) នៃដែនដី នៃកោះទាំងនេះ នៅទុកដោយឡែកដដែល។

សូមលោក ចាត់វិធានការណ៍ ដើម្បីឲ្យការសម្រេចរបស់ខ្ញុំនេះ ចូលជាធរមានដោយប្រញាប់។

(ហត្ថលេខា) **ប្រេវីយេ (Brévié)**